Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 2/1 (January 2001): 99–110



# Indigenization of a National Church

## A Reflection on Cambodian Church Structure

*Arun SOK NHEP*

### Introduction

The concept of indigenization is not new to Christianity. We read about it as early as Paul's ministry in the book of Acts. Gentile churches, while keeping a close relationship with the mother church in Judea, had difficulty adopting Jewish practices such as circumcision. Paul, as a missionary to the Gentiles, understood the need of the Gentiles to be themselves. He defended their cause and convinced the Jewish Christians not to impose their own customs and lifestyle on the Gentiles (Acts 15).

Everywhere the gospel is proclaimed Christianity has to work toward making the Church indigenous. Presently, church culture seems to be moving towards Western—and especially American—paradigms in music, worship, structure, strategy, evangelism methods, etc. This trend also occurs here in Cambodia.

Unfortunately, in process of church planting, not only were the gospel and a Christian worldview transmitted, but western church culture as well. As a result, the Cambodian church as a whole seems disconnected from its own socio-cultural environment. This puts believers under pressure, as they are torn between the cultural system transmitted by missionaries and their own cultural system. Christians are perceived by their compatriots as traitors, and become strangers within their own culture. Some missionaries and national leaders are aware of the problem of

western acculturation but do not know how to make the appropriate changes.

The purpose of this article is to learn from what has been written about contextualization with its benefits and dangers, and to provide a reflection (but not a model) on how a contextualized Cambodian Church may be conceived.

## Indigenization

Nowadays missionaries are evaluated not only by their accomplishments in evangelizing a nation, but also by their ability to indigenize the churches they establish. Consequently, most mission societies orient their objectives toward the training of national leaders so that, in turn, the nationals can take over the leadership of their own churches.

According to Soltau, a church is indigenous when "it becomes native to the country and grows there naturally, as part and parcel of the people among whom it has been planted."[1]

Smalley defines an indigenous church as "a group of believers who live out their life, including their socialized Christian activity, in the patterns of the local society, and for whom any transformation of that society comes out of their felt needs under the guidance of the Holy Spirit and the Scriptures."[2]

In practice, however, a local church is judged to be indigenized or not based on its autonomy in leadership, finance, and propagation strategy. This autonomy is often labeled as *the three-self formula:* "self-governing, self-supporting, and self propagating."

Self-governing churches are not necessarily indigenous, because national leaders are often trained in western patterns of church government. They are not really oriented to organizing the

---

[1]T. S. Soltau, *Missions at the Crossroads* (Grand Rapids: Baker, 1994), 20.

[2]Article in *Perspectives on the World Christian Movement*, ed. R. D. Winter and S. C. Hawthorne (Pasadena: William Carey Library, 1981), 497.

church from their own socio-cultural perspective, but rather blindly imitate the western church culture. In fact, nationals often serve as figureheads in the leadership while missionaries exercise the real power over the local churches because of the financial support they provide. "Self-supporting" is also often considered a barometer of success in indigenization. National churches are encouraged to meet their needs financially and support their leaders. They are also encouraged to establish local strategies to share the gospel with their own people. But the methods used, whether in financial matters or in evangelism strategies (crusades, campaigns, etc.), are often not different from those of the west.

But indigenization entails more than this three-self formula; it requires deep reflection on and evaluation of the cultural identity of a national church. This leads to the next and probably most important step in the process of indigenization—contextualization.

## Contextualization

According to Lingenfelter, contextualizing means "to frame the gospel message in language and communication forms appropriate and meaningful to the culture and to focus the message upon crucial issues in the lives of the people."[3]

**Contextualization: reaction to colonialism.** Unfortunately, in the past the history of mission has been closely linked to colonialism. Mission opened a door for western colonization, and colonization allowed missionaries to establish the church in remote areas of the world.

During the colonial era, encounters between western and other nations resulted in a feeling of superiority on the part of white people because of their advanced science and technology. Consequently, western culture was considered superior to other

---

[3]Sherwood G. Lingenfelter, *Transforming Culture—A Challenge for Christian Mission*, 2nd ed. (Grand Rapids: Baker, 1998), 1.

cultures, and often it was labeled simply as "the culture" in contrast to others termed "primitive".

Missionaries during that period were affected by the spirit of their times. They organized the church molded on western culture. In their reasoning, "the West's obvious superiority over other cultures proved the superiority of Christian over pagan religions."[4] And these "primitive" nations did need not only salvation, but also civilization! For instance, "in 1890, T. W. Pearce pointed out that merely introducing Christianity to China was not enough, Western civilization, in its entirely, had to overcome Chinese civilization."[5] For this reason, even today one can notice a strongly western culture within Chinese churches.

In the same spirit, they translated the Bible using the literal translation principle (often from the King James Version) and did not care about the linguistic or cultural sensibilities of the receptive languages. Often witnessing to the gospel was combined with English teaching so that new believers could find better jobs and attain higher economic status. Thus, Anglo-culturization was sometimes perceived by missionaries and national as superior to local culture.

Although the colonial era thus entailed such negative aspects as arrogance and segregation, we have to admit the positive side of that period: the gospel was proclaimed, regardless of how it was transmitted;[6] the Bible was translated into many languages; churches, hospitals, and educational systems were established.

But the anti-colonial movement brought to an end racial segregation within the church, at least on the ethic level. The superiority of western culture was questioned; western Christians started to discern between the gospel and their own culture. They also began taking other cultures seriously and sought to understand them. Consequently, more and more missionaries encouraged

---

[4]Paul G. Hiebert, *Anthropological Reflections on Missiological Issues* (Grand Rapids: Baker, 1994), 55.

[5]Ibid.

[6]Phil 1:18.

indigenous leaders to present the gospel with a local context and theology. The local church must seek to "integrate the Gospel message (*the text*) with its local culture (*the context*). The text and context must be blended into that one, God-intended reality called *Christian living.*"[7]

**The dangers of contextualization.** However, contextualization also has its drawbacks, especially when there is a tendency to perceive all cultures as good. Other religions may also be considered as a revelation of God, and therefore may open a door to syncretism. As a result the uniqueness of Christ and his salvation are questioned. Christ may be presented as only *one* way to the Father, and not *the* way.

This could also lead to the other extreme—rejecting everything from the West, even its good principles.

**Critical contextualization.** In order to benefit from contextualization and avoid dangers of dragging, the process must be undertaken with care. I think the task of contextualization should undertaken by local leaders and missionaries (preferably from different nationalities) together. A local leader has ability to discern and feel what is good or bad in his culture. But the role of the missionary is also important in providing a framework. Before making any exegesis of a culture, one should seek first to understand that culture.

Kwast[8] believes that understanding a culture is like peeling different layers. The first layer is to study the *behavior* of the people. Second, understand their *values*. Third, probe the deeper level of *beliefs*: what they hold to be true. Finally, at the very heart of any culture lies its *worldview*: what is real to people. This last has to be taken into account when sharing the gospel.

---

[7]L. J. Luzbetak, *The Church and Cultures,* (Maryknoll, New York: Orbis, 1988), 72.

[8]In an article published in C. H. Kraft and T. N. Wisley, eds., *Readings in Dynamic Indigeneity* (Pasadena: William Carey Library, 1979).

Hesselgrave[9] argues that the missionary has his own cultural background, which embodies his own worldview and standard of values. He himself received the message of the Bible within his own specific cultural context. This is the "missionary's culture." He has to transmit the message to another culture with its distinct worldview and value system. This is the "target culture." The temptation is ever present to project the cultural background of the missionary into the process and therefore blur the original meaning of the Bible's message. The missionary must take into account the target culture with its value system. He must remember that the ideas of this culture are as strong as those from his own. His audience will project their own understanding into the message of the Bible. The missionary must strive to communicate in a way that is relevant to the target culture while still remaining faithful to the original message. This is a most difficult task.

Therefore the responsibility of the missionary is heavy, as he has to lead and train leaders in the respondent culture. National pastors have often proved even worse in spreading a western message with little relevance to their own culture. The consequences are both disastrous and lasting. What is done is difficult to undo.

Hesselgrave believes that communication between the missionary and the target culture is often a monologue—from missionary to respondent. The missionary only relates the message without trying to understand the respondent culture and worldview. Nothing will be gained by ridiculing or pointing to inconsistencies in the beliefs. The message of the gospel is universal. The Christian message remains the same for all times and all cultures. Contextualization is essential for the message to be understood and accepted.

In the case study of the Cambodian church, I would like to leave aside the theological aspects of contextualization, and emphasize the institutional structure of the indigenized church.

---

[9]In an article published in Kraft and Wisley, *Readings*.

## The Cambodian Church

Every society is a system. In order to function efficiently, any system needs to be balanced and harmonious. According to Mayers, "all the parts of the systems relate to the whole and give it meaning. The whole, in turn, gives meaning to the parts. Without the whole, the parts would have no reason for existing; and without any one of the parts, there would be no whole."[10]

A local church, although spiritual part of the Kingdom of God, also remains part of a definite socio-cultural group. The church is called to transform its environment with the gospel without becoming unnecessarily foreign to the socio-cultural system.

The church of Cambodia has manifested a desire to indigenize, and missionaries are working to relinquish the leadership to national Christians. Nevertheless, non-Christian Cambodians still consider the church to be foreign, since the church culture and institutional structure are unfamiliar to most people. For a Cambodian, to become a Christian is not an easy thing—he experiences not only a spiritual transformation, but has to adapt to western church culture. For this reason, most of the churches have a difficult time in discipling new believers, as they tend to return to Buddhism after a brief sojourn in Christianity. I think this phenomenon is due to cultural nostalgia, because the church has neglected the importance of contextualization. I believe that indigenization without contextualization is ineffective.

**Learning from history.** Portuguese Dominican missionaries arrived in Cambodia in the mid-sixteenth century. Buddhism had entered a few centuries previously, and experienced such expansion that it superseded Hinduism as the national religion. Christianity never enjoyed such success. Buddhism succeeded in its indigenization.

---

[10]M. Myers, *Christianity Confronts Culture* (Grand Rapids: Zondervan, 1987), 95.

In 1975 the Roman Catholic Church counted only a few hundred members in its fold.[11] Leadership was exercised by French bishops and priests. Although the Catholics took great pains to inculturate, the French missionaries did not seem ready to relinquish leadership to nationals. Only two or three Khmer priests were ordained, and the first Khmer bishop was ordained at the last minute because foreigners had to leave the country before the Khmer Rouge took over the country in 1975. Therefore the Catholic Church is perceived by the population as a French religion.

Protestant missionaries from Christian and Missionary Alliance arrived in Cambodia in 1923. This mission focused on indigenization. The three-self formula was (and is) widely implemented in this denomination. But the church was then supervised by missionaries, and church structure is often based on American models. Because of this, the church was perceived as an American religion.

Unfortunately during the Khmer-Rouge period (1975–79), as the whole country was plunged into genocide, Catholic and Protestant churches shared the same fate: the Khmer bishop and priests were executed, and out of forty pastors only four survived. Churches were destroyed, Christians dispersed, and the majority perished.

**The contemporary Cambodian church.** When the post-communist regime was proclaimed in Cambodia in 1991, the surviving Christians rebuilt the church. As the church grows, and as more national Christians assume leadership, it is time to think about how to contextualize church structure so that it fits local culture. Most missionaries and Cambodian leaders have noticed that evangelizing the Khmer people is easy, but keeping them

---

[11]In 1955 the Cambodian Roman Catholic Church had 120,000 members. But during the Indochinese independence process, France gave to Vietnam the Cochin China, which used to be Khmer provinces and where the majority of Cambodian Catholics live. This explains one of the reasons why modern Cambodia counts only a few hundred Catholics.

faithful to Christian living is hard. This is due to the fact that the believers do not know how to live as Christians in Khmer society, since the whole church structure is alien to Cambodians. For this reason it is important to reconsider the form of Christianity, so that the church of Christ may have a local look, rather than a French or American face.

## Understanding Khmer socio-cultural structure

The first step in the process is seeking to understand the Cambodian social structure. Cambodian society is organized according to a corporate social environment. Hierarchy is very important to Cambodians. For instance, when missionaries start to learn the Khmer language they will realize very soon that one of the main characteristics is that it is built upon a hierarchical system. Thus there are at least four levels of vocabulary. One cannot talk to God, to the king, to monks, teachers, parents, or friends, using the same vocabulary. Each set of vocabulary is used for each specific level of society.

In the traditional structure, hierarchy is based not only on the role that one may play in society but also on seniority. Wisdom is often associated with age. Normally a young man is not in a good position to teach elderly people. Missions have a tendency to focus their effort on training young people, because of their ability to learn the western way. The elderly people are neglected; as a result they think that evangelism or other tasks for God are a young person's job. Consequently, the church has lost a natural way to impact its community. In a society like Cambodia's, we should not neglect and underestimate the importance of the elderly.

Another important aspect that one should not overlook is that religious life in Cambodia is organized around monasticism. The concept of the church with a salaried priest or pastor working in an office is not familiar to Cambodians. For this reason, pastors are often considered more as mission employees or civil servants than religious or spiritual leaders.

## Two possible patterns

Establishing the Kingdom of God entails not only proclaiming the gospel but building a community of believers in a specific socio-cultural context. The church as a religious institution ought to be structured in a form that is culturally natural. In a hierarchical society "the cooperate interests of the group place significant constrains upon leaders."[12] The Cambodian church leadership could be structured on the two following models:

1. *Presbyterian* form: In the Khmer tradition, a position of authority and seniority often tend to be synonymous. For the instance, the king is respected not simply because he is king, but also because of his seniority. The social and religious activities are usually organized by a group of elderly lay men, the *Achars*, who lead the Buddhist community in worship and ceremonies. In the temple, they fulfill the role of mediator between the Buddhist monks and the believers. (Since a Christian pastor looks like a layman, in contrast to a Buddhist monk, he is often named the *Achar* by non-Christians. He is thus perceived as less important than a monk.) .The *Achars* normally have a secular job; their involvement in religious life is merely voluntary.

A church organized with a "Council of Elders" may have more impact on the community than a church led by a sole pastor. Such a structure would not only be familiar to the Khmer people, but its foundation closely reflects the New Testament pattern. Furthermore, the requirements of the elders can also be found in the Scripture.[13]

2. *Monastic* form: Traditionally, the Cambodian pagoda is central not only for religious life, but also for social and educational life, where a group of people live together as a learning, praying, and meditating community. Young monks gather around elder priests and commit themselves to live in poverty and chastity (at least in theory). They spend their time in meditating and learning the Buddhist scriptures. But unlike

---

[12]Lingenfelter, *Transforming Culture*, 134.

[13]1Tim 3:1–7; Tit 1:5–9.

monastic life in Europe, these monks interact every day with secular society through ceremonies and teachings. They also receive their food and gifts from the population. This could be serve as a model for Cambodian Christians who want to commit themselves entirely to God without being entirely disconnected from the world. One may see connection between this lifestyle and the experience of Jesus and his disciples. The disciples gathered around the Master while learning and interacting with the population.

In the past, Benedictine monks organized monastic life Cambodian style, but they failed to flourish. I think this is due to the uncritical concept of contextualization. For instance, they practiced flagellation, which is not familiar to the Khmer people.

In the process of contextualization, only the external form should be structured with a local paradigm (perhaps also evangelism and theologizing methods), but the core of the gospel, that is salvation in Jesus Christ, must remain intact. What the people need is not a local or imported religion, but to be transformed by the gospel.

## Conclusion

An indigenized church is not simply one led by national leaders imitating western church culture. Indigenizing a church should not mean that we have to reject the principles and values of other churches. As part of the universal church we ought to live and share together our discovery in our pilgrim life with the Lord.

We must be aware that church cannot be completely integrated into its cultural setting. We cannot conform ourselves entirely to our society, lest we may go astray from the One who called us. In the process of indigenizing the church we ought to think about transforming our culture by bringing the spirit of the gospel into it, instead of bringing its spirit to the gospel. "Transformation is neither bridging form one system to another or transferring a Christian system to another place and people. Rather, transformation means a new hermeneutic—a redefinition, a

reintegration of the lives of God's people (the Church) within the system in which they find themselves living and working."[14]

[14]Lingenfelter, *Transforming Culture*, 18.

សំណុំឆឹកឃ្មុំ ២/១ (មករា ២០០១)៖ ១១១-១២៨



# ការធ្វើឲ្យពួកជំនុំក្នុងស្រុកមានលក្ខណៈម្ចាស់ការ

## ការឆ្លុះបញ្ចាំងមួយទៅលើរចនាសម្ព័ន្ធពួកជំនុំកម្ពុជា

សុខ ញិប *អារុណា*

### សេចក្ដីផ្ដើម

គោលគំនិតស្ដីពីការបង្កើតពួកជំនុំឲ្យមានលក្ខណៈម្ចាស់ការ គឺមិនមែនជារឿងថ្មីចំពោះគ្រីស្ទបរិស័ទទេ ។ យើងបានអានពីរឿងនេះ តាំងតែពីព័ន្ធកិច្ចដើមដំបូង របស់លោកសាវ័ក ប៉ូល នៅក្នុងកណ្ឌគម្ពីរកិច្ចការ ។ កាលកំពុងបន្តទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយពួកជំនុំមេនៅស្រុកយូដា ពួកជំនុំសាសន៍ដទៃទាំងឡាយបានជួបការលំបាក ក្នុងការទទួលយកការអនុវត្តន៍នានារបស់ជនជាតិជ្វីហ្វ (យូដា) ដូចជា ការកាត់ស្បែកជាដើម ។ លោក ប៉ូល ដែលជាសាសនទូតម្នាក់សំរាប់សាសន៍ដទៃ បានយល់ពីសេចក្ដីត្រូវការរបស់សាសាន៍ដទៃ ក្នុងការធ្វើជាម្ចាស់ការរបស់ពួកគេ ។ លោកបានការពារផលប្រយោជន៍របស់ពួកគេ និងបានធ្វើឲ្យពួកគ្រីស្ទបរិស័ទយូដាជឿយ៉ាងស៊ុប ដោយមិនរំលោភលើទំនៀមទំលាប់ និង ជីវភាពផ្ទាល់ខ្លួនរបស់ពួកគេទៅលើពួកសាសន៍ដទៃឡើយ (កិច្ចការ ១៥) ។

នៅគ្រប់ទីកន្លែង ដែលដំណឹងល្អត្រូវបានប្រកាសផ្សាយ នោះជំនឿគ្រីស្ទបរិស័ទត្រូវតែធ្វើការឆ្ពោះទៅរកការបង្កើតពួកជំនុំដើមមួយ ។ បច្ចុប្បន្ននេះ វប្បធម៌ពួកជំនុំហាក់ដូចជា កំពុងរំកិលទៅរកពួកលោកខាងលិច ជាពិសេសអាម៉េរិកាំង គឺថាចម្លងតាមតន្ត្រី ការថ្វាយបង្គំ រចនា

សម្ព័ន្ធ យុទ្ធសាស្ត្រ វិធីសាស្ត្រផ្សាយដំណឹងល្អ ។ល។ និន្នការទាំងនេះ ក៏កើតមានឡើងផងដែរនៅក្នុងប្រទេសកម្ពុជា ។

គួរឲ្យស្តាយក្នុងដំណើរការនៃការបង្កើតពួកជំនុំ មិនមែនគ្រាន់តែជាដំណឹងល្អ និង ជាគតិលោករបស់គ្រីស្ទបរិស័ទមួយ ដែលបានបញ្ជូន ឬ ជះឥទ្ធិពលប៉ុណ្ណោះទេ តែថែមទាំងវប្បធម៌ពួកជំនុំលោកខាងលិចផងដែរ ។ ជាលទ្ធផល និង ជារូបភាពធំ ពួកជំនុំកម្ពុជាហាក់បីដូចកាត់ផ្តាច់ចេញពីវប្បធម៌ និង សង្គមរបស់ខ្លួន ដែលប្រការនេះធ្វើឲ្យពួកអ្នកជឿស្ថិតនៅក្រោមសម្ពាធ គឺថាពួកគេត្រូវបានរហែកជាពីរ ដោយសារប្រព័ន្ធវប្បធម៌ដែលបានបញ្ជូនមកដោយសារពួកសាសនទូត និងប្រព័ន្ធវប្បធម៌ផ្ទាល់របស់ពួកគេ ។ គ្រីស្ទបរិស័ទត្រូវបានជនរួមជាតិរបស់ខ្លួន ចាត់ទុកថាជាជនក្បត់ ហើយក្លាយជាជនចម្លែក នៅក្នុងវប្បធម៌របស់ខ្លួនឯងទៀតផង ។ បេសកជនខ្លះនិងអ្នកដឹកនាំជាតិមួយចំនួន យល់ដឹងអំពីបញ្ហានៃការយកលំនាំតាមលោកខាងលិចនេះយ៉ាងច្បាស់ ប៉ុន្តែមិនដឹងពីរបៀបដែលត្រូវធ្វើការ ផ្លាស់ប្តូរឲ្យសមរម្យទាល់តែសោះ ។

គោលបំណងនៃប្រធានបទនេះ គឺដើម្បីរៀនពីអ្វី ដែលបានចារទុកមកអំពីបរិបទូបនីយកម្ម ( ធ្វើឲ្យស៊ីនឹងស្ថានការណ៍ ) ជាមួយនឹងផលប្រយោជន៍ និង គ្រោះថ្នាក់ទាំងឡាយរបស់វា និង ដើម្បីផ្តល់នូវការឆ្លុះបញ្ចាំងមួយ ( ប៉ុន្តែមិនមែនជាគំរូទេ ) ទៅលើរបៀបដែលពួកជំនុំកម្ពុជាអាចចាប់យកបាននូវបរិបទូបនីយកម្មត្រឹមត្រូវនេះ ។

## ការធ្វើឲ្យមានភាពម្ចាស់ការ

សព្វថ្ងៃនេះ បេសកជនទាំងឡាយត្រូវបានគេវាយតម្លៃមិនគ្រាន់តែដោយស្នាដៃរបស់ពួកគេ ក្នុងការផ្សាយដំណឹងល្អ ដល់ប្រជាជាតិមួយប៉ុណ្ណោះទេ តែក៏ដោយសារលទ្ធភាពរបស់ពួកគេក្នុងការផ្តល់កំណើតពួកជំនុំ ដែលពួកគេបង្កើតឡើង ។ ជាលទ្ធផល សមាគមបេសកកម្មទាំងឡាយតំរង់គោលដៅរបស់ពួកគេ ឆ្ពោះទៅកាន់ការហ្វឹកហ្វឺនអ្នកដឹកនាំក្នុង

ស្រុក ដើម្បីឲ្យជនជាតិទាំងនោះអាចបន្តវេណស្នងភាពជាអ្នកដឹកនាំនៃពួកជំនុំរបស់ពួកគេដោយខ្លួនគេបាន ។

យោងតាមលោក សូលតូ ថ្លែងថាពួកជំនុំមួយដែលមានលក្ខណៈម្ចាស់ការកាលណា "ពួកជំនុំនោះក្លាយជាម្ចាស់ស្រុក ចំពោះប្រទេសនោះ ហើយរីកលូតលាស់ជាធម្មតាជាផ្នែក និងជាភាគតូចៗនៃមនុស្ស នៅក្នុងចំណោមដែលពួកជំនុំត្រូវបានបង្កើតឡើង[១]"

លោក ស្មាលី ឲ្យអត្ថន័យថា ពួកជំនុំមួយដែលមានលក្ខណៈម្ចាស់ការគឺជា "អ្នកជឿមួយក្រុម ដែលមានជីវិតរស់នៅ ដោយរាប់បញ្ចូលទាំងសកម្មភាពសង្គមរបស់គ្រីស្តបរិស័ទ នៅក្នុងគំរូនៃសង្គមមូលដ្ឋាន និងទាំងសំរាប់អស់អ្នកណា ដែលការផ្លាស់ប្តូរណាមួយរបស់សង្គមនោះកើតចេញពីសេចក្តីត្រូវការ ដែលស្ថិតនៅក្រោមការដឹកនាំរបស់ព្រះវិញ្ញាណ និង បទគម្ពីរ[២]" ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តន៍ជាក់ស្តែង ពួកជំនុំមូលដ្ឋានមួយត្រូវបានគេវិនិច្ឆ័យថាជា ពួកជំនុំម្ចាស់ការ ឬ មិនមែនដោយអាស្រ័យលើស្វ័យភាពរបស់ពួកជំនុំ ក្នុងភាពជាអ្នកដឹកនាំ ហិរញ្ញវត្ថុ និងការផ្សព្វផ្សាយដំណឹងល្អ ដែលជាញឹកញាប់ត្រូវបានគេឲ្យឈ្មោះថា *រូបមន្តត្រីស្វ័យភាព:* "ស្វ័យាភិបាល ស្វ័យូបត្ថម្ភ និង ស្វ័យបេសកកម្ម" ។

ពួកជំនុំស្វ័យាភិបាល មិនមែនសុទ្ធតែជាពួកជំនុំដែលមានលក្ខណៈម្ចាស់ការទេ ពីព្រោះអ្នកដឹកនាំជាតិនោះជាញឹកញាប់ត្រូវបានហ្វឹកហ្វឺន នៅក្នុងគំរូនៃការគ្រប់គ្រងរបស់ពួកជំនុំបែបលោកខាងលិច ។ ពួកគេមិនត្រូវបានណែនាំយ៉ាងពិតប្រាកដ ក្នុងការរៀបចំពួកជំនុំចេញពីទស្សនៈវប្បធម៌

---

[1] T. S. Soltau, *Missions at the crossraods* (Grand Rapids: Baker, 1994), 20.

[2] Article in *Perspectives on the World Christian Movement,*ed. R.D. Winter and S. C. Hawthrone (Pasadena: William Carey Library, 1981), 497

និង សង្គមផ្ទាល់របស់ពួកគេទេ តែបែរជាត្រាប់តាមទាំងងងឹតងងុលនូវវប្បធម៌ពួកជំនុំលោកខាងលិច ។ តាមការពិត ម្ចាស់ស្រុកជាញឹកញាប់បំរើក្នុងនាមជាអ្នកដឹកនាំមានតែឈ្មោះ ក្នុងខណៈដែលពួកបេសកជនប្រតិបត្តិនូវអំណាចពិតប្រាកដទៅលើពួកជំនុំមូលដ្ឋាន ដោយសារតែការផ្គត់ផ្គង់ខាងហិរញ្ញវត្ថុ ដែលពួកគេផ្តល់ឲ្យ ។ ជារឿយៗ "ស្វ័យបត្ថម្ភ" ត្រូវបានគេចាត់ទុកថាជា បារ៉ូម៉ែត្រនៃជោគជ័យ (ជោគជ័យមានតែក្នុងគំនិត) ក្នុងការធ្វើឲ្យមានលក្ខណៈម្ចាស់ការ ។ ពួកជំនុំជាតិត្រូវបានលើកទឹកចិត្តឲ្យបំពេញសេចក្តីត្រូវការរបស់ពួកគេខាងផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់អ្នកដឹកនាំរបស់ពួកគេ ។ ពួកគេក៏ត្រូវបានលើកទឹកចិត្តផងដែរ ក្នុងការស្ថាបនាយុទ្ធសាស្ត្រមូលដ្ឋានទាំងឡាយ ដើម្បីប្រកាសដំណឹងល្អ ជាមួយប្រជារាស្ត្ររបស់ពួកគេផ្ទាល់ ។ ប៉ុន្តែវិធីសាស្ត្រទាំងឡាយ ដែលបានប្រើទោះជាបញ្ហាខាងហិរញ្ញវត្ថុ ឬនៅក្នុងយុទ្ធសាស្ត្រនៃការផ្សាយដំណឹងល្អក្តី (ការប្រកាសដំណឹងល្អជាទ្រង់ទ្រាយធំ ការធ្វើយុទ្ធនាការ ។ល។ ) គឺជាញឹកញាប់មិនខុសពីពួកលោកខាងលិចឡើយ ។

ប៉ុន្តែការធ្វើឲ្យមានលក្ខណៈម្ចាស់ការ តម្រូវឲ្យមានច្រើនលើសជាងរូបមន្តត្រីស្វ័យភាពនេះទៅទៀត គឺថាវាតម្រូវឲ្យមានការឆ្លុះបញ្ចាំងដ៏ស៊ីជំរៅទៅលើពួកជំនុំជាតិមួយ ហើយនិង ការវាយតម្លៃអំពីអត្តសញ្ញាណវប្បធម៌របស់ពួកជំនុំជាតិមួយនោះដែរ ។ ប្រការនេះហើយ ដែលនាំទៅរកជំហានបន្ទាប់ ហើយប្រហែលជាជំហានមានលក្ខណៈដ៏មានសារៈសំខាន់ក្នុងដំណើរការ នៃការធ្វើឲ្យមានលក្ខណៈម្ចាស់ការ មានន័យថា ការធ្វើឲ្យស៊ីនឹងស្ថានការណ៍ដ៏ត្រឹមត្រូវ ។

## បរិបទូបនីយកម្ម

យោងតាមលោក លីងហ្សង់ហ្វីលទ័រ ឲ្យអត្ថន័យថា បរិបទូបនីយកម្មត្រឹមត្រូវគឺការដាក់ក្របខ័ណ្ឌដល់រាជសារនៃដំណឹងល្អជាភាសាហើយការប្រាស្រ័យទាក់ទងបង្កើតឡើងយ៉ាងសមរម្យ និង មានអត្ថន័យចំពោះ

វប្បធម៌ និង ដើម្បីផ្តោតទៅលើសារនៃព្រះបន្ទូល ដែលជាបញ្ហាសំខាន់នៅក្នុងជីវិតរបស់បណ្តាជន៣" ។

បរិបទូបនីយកម្មៈ ប្រតិកម្មចំពោះអាណានិគមនិយម គួរឲ្យស្តាយកាលពីអតីតនៅក្នុងប្រវត្តិសាស្ត្រនៃបេសកកម្មកន្លងទៅ ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងអាណានិគមនិយម ។ បេសកកម្មបានបើកទ្វារសំរាប់ការធ្វើអាណានិគមរបស់លោកខាងលិច ហើយការធ្វើអាណានិគមទៀតសោតអនុញ្ញាតឲ្យសាសនទូត បង្កើតពួកជំនុំនៅតាមតំបន់ដែលដាច់ស្រយាលនៃផែនដី ។

នៅក្នុងសករាជនៃអាណានិគម ការពើបប្រទះរវាងលោកខាងលិច និង ប្រជាជាតិដទៃទៀត បានហុចលទ្ធផលឧត្តមភាពពួកស្បែកស ប្រើអំណាចគ្របដណ្តប់លើម្ចាស់ស្រុក ដោយសារតែភាពជឿនលឿនផ្នែកបច្ចេកវិជ្ជា និង វិទ្យាសាស្ត្ររបស់ពួកគេ ។ ផលវិបាកដែលកើតឡើង វប្បធម៌លោកខាងលិច ត្រូវបានចាត់ទុកថា ខ្ពស់ជាងវប្បធម៌របស់ម្ចាស់ស្រុក ហើយជាញឹកញាប់វាត្រូវបានគេឲ្យឈ្មោះយ៉ាងសាមញ្ញថា "វប្បធម៌ឧត្តម" ផ្ទុយទៅនឹងវប្បធម៌ម្ចាស់ស្រុក ដែលត្រូវគេឲ្យឈ្មោះថា "វប្បធម៌ចាស់គំរិល" ។

នៅក្នុងអំឡុងពេលនោះ ពួកសាសនទូតបានទទួលឥទ្ធិពល ដោយសារស្មារតីនៃសម័យកាលរបស់ពួកគេ។ ពួកគេបានរៀបចំគំរូពួកជំនុំតាមវប្បធម៌លោកខាងលិច ។ នៅក្នុងហេតុផលរបស់ពួកគេគឺថា "ឧត្តមភាពរបស់ពួកលោកខាងលិចខ្ពស់ជាងវប្បធម៌ដទៃ បានសឲ្យឃើញពី ឧត្តមភាព នៃគ្រីស្តបរិស័ទទៅលើពាហិរសាសនានៃពួកអ្នកមិនជឿព្រះគ្រីស្ត៤" ហើយប្រជាជាតិ "អន់ថយ" ទាំងនេះ ពិតជាមិនគ្រាន់តែត្រូវការសេចក្តី

---

[3] Sherwood G. Lingenfelter, *Transforming Culture—A challenge for Christian Mission* (Grand Rapids: Baker, 1998), 1

[4] P. G. Hiebert, *Anthropological Reflections on Missiological Issues* (Grand Rapids: Baker, 1994), 55.

សង្គ្រោះប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការអារ្យធម៌ផងដែរ! ជាតួយ៉ាង "នៅក្នុងឆ្នាំ ១៨៩០ លោក ធ. វ. ភាស (T. W. Pearce) បានបង្ហាញថា គ្រាន់តែណែនាំជំនឿគ្រីស្តបរិស័ទដល់សាធារណរដ្ឋប្រជាមានិតចិន គឺវាមិនគ្រប់គ្រាន់ទេ គឺអារ្យធម៌លោកខាងលិចទាំងមូល បានគ្របដណ្តប់អារ្យធម៌ចិន[5]" ព្រោះហេតុផលនេះ សូម្បីតែសព្វថ្ងៃនេះនរណាម្នាក់ក៏អាចសំគាល់ថា វប្បធម៌លោកខាងលិចបានជ្រាបចូលយ៉ាងធ្ងន់ធ្ងរទៅក្នុងពួកជំនុំចិន ។

នៅក្នុងស្មារតីដូចគ្នានេះ ពួកគេបានបកប្រែព្រះគម្ពីរប៊ីប ដោយប្រើគោលការណ៍បកប្រែតាមពាក្យត្រង់ៗ (ជារឿយៗតាមព្រះគម្ពីរ ឃីង ជែម វើរស្សិន "King James Version" ) ហើយមិនខ្វាយខ្វល់អំពីភាពផ្ទុយគ្នា ឬភាពសមហេតុផលនៃវប្បធម៌របស់ភាសា ដែលត្រូវទទួលយក ។ ជាញឹកញាប់ការធ្វើបន្ទាល់ដំណឹងល្អ ត្រូវបានភ្ជាប់ការបង្រៀនភាសាអង់គ្លេសប្រយោជន៍ឲ្យអ្នកជឿថ្មីអាចរកការងារបានល្អ ហើយទទួលបានជីវភាពរស់នៅខ្ពស់ជាងមុន ។ ដូច្នោះ ការសាបព្រោះវប្បធម៌អង់គ្លេសូបនីយកម្ម ជួនកាលត្រូវបានទទួលដោយពួកសាសនទូត និង ពួកម្ចាស់ស្រុកនោះថា មានឧត្តមភាពជាងវប្បធម៌ក្នុងស្រុក ។

ដូច្នេះ ថ្វីដ្បិតតែសម័យអាណានិគម បន្សល់ទុកនូវទិដ្ឋភាពអវិជ្ជ-មាន (ចំណុចអាក្រក់) ដូចជាភាពក្រអឺតក្រទម និង ការបែងចែកក្រុមបក្ខក៏ដោយ ក៏យើងត្រូវតែទទួលស្គាល់ផងដែរ នូវទិដ្ឋភាពវិជ្ជមាន (ចំណុចល្អ) នៃសម័យកាលនោះដូចជាការប្រកាសដំណឹងល្អ បានធ្វើឲ្យគេពុស្សុះសាយ ទោះប្រកាសផ្សព្វផ្សាយដោយរបៀបណាក៏ដោយ[6] ការសាបព្រោះវប្បធម៌អង់គ្លេសូបនីយកម្ម គេបានបកប្រែព្រះគម្ពីរប៊ីប ជាច្រើនភាសា គេបានស្ថាបនាពួកជំនុំ មន្ទីរពេទ្យ និង ប្រព័ន្ធសិក្សាអប់រំជាច្រើន ។

---

[5] Ibid.

[6] *ភីលីព ១:១៨*

ប៉ុន្តែចលនាប្រឆាំងនឹងអាណានិគម បានបញ្ចប់នូវការបែងចែកពូជសាសន៍នៅក្នុងពួកជំនុំ ដែលយ៉ាងហោចណាស់ក៏បានបញ្ចប់ក្នុងការបែងចែកសីលធម៌ផងដែរ ។ ឧត្តមភាពនៃវប្បធម៌របស់លោកខាងលិច ត្រូវបានគេចោទសួរគ្រីស្តបរិស័ទ លោកខាងលិចក៏ចាប់ផ្តើមយល់ដឹងរវាងដំណឹងល្អ និង វប្បធម៌របស់ខ្លួន ។ ពួកគេក៏ចាប់ផ្តើមទទួលយកវប្បធម៌របស់ម្ចាស់ស្រុកយ៉ាងហ្មត់ចត់ ហើយបានស្វែងយល់អំពីវប្បធម៌នោះ ។ បន្ទាប់មកពួកបេសកជន បានលើកទឹកចិត្តអ្នកដឹកនាំក្នុងស្រុកឲ្យប្រកាសដំណឹងល្អឲ្យស៊ីនឹងស្ថានការណ៍ និង ស្របតាមទេវសាស្ត្រក្នុងស្រុក ។ ពួកជំនុំមូលដ្ឋានត្រូវតែស្វែងរកនូវ "ការផ្សារភ្ជាប់ព្រះរាជសារនៃ (អត្ថបទ) ដំណឹងល្អឲ្យស៊ីនឹងវប្បធម៌ក្នុងតំបន់របស់ខ្លួន *(បរិបទ)* ។ អត្ថបទ និង បរិបទ ត្រូវតែលាយបញ្ចូលគ្នា ឲ្យក្លាយទៅជាតែមួយ ដែលជាសេចក្តីពិតដែលព្រះទ្រង់ប្រាថ្នា គឺបានហៅថា ការរស់នៅរបស់គ្រីស្តបរិស័ទ[7]" ។

**គ្រោះថ្នាក់នៃបរិបទូបនិយកម្ម:** ទោះជាយ៉ាងណាក៏ដោយ ក៏បរិបទូបនិយកម្មត្រឹមត្រូវ មានចំណុចខ្សោយរបស់វាដែរ ជាពិសេសនៅពេលមានទំនោរមួយទៅរកការទទួលយកនូវវប្បធម៌ទាំងអស់ថាល្អ ។ គេក៏ទទួលស្គាល់ថាសាសនាដទៃទៀត ក៏ជាការបើកសម្តែងមកពីព្រះជាម្ចាស់ដែរ ដូច្នេះការនេះក៏បើកទ្វារ ឲ្យមានការរិះគន់យ៉ាងចម្រូងចម្រាសចូលមក ។ ហេតុដូច្នេះបានជាឯកលក្ខណៈភាព (លក្ខណៈពិសេស) របស់ព្រះគ្រីស្ត និង សេចក្តីសង្គ្រោះរបស់ព្រះអង្គត្រូវបានចោទសួរយ៉ាងខ្លាំងៗ ។ គេបានបង្ហាញឲ្យឃើញថា ព្រះគ្រីស្តអាចជាផ្លូវមួយទៅកាន់ព្រះបិតាតែមិនមែន ជាផ្លូវតែមួយគត់នោះឡើយ ។ ការនេះអាចនាំទៅកាន់ភាពជ្រុល

[7] L. Luzbetak, *the Church and Cultures*, (Maryknoll, New York: Orbis, 1988),72

និយម ដទៃទៀតផងដែរ គឺការបដិសេធចោលអ្វីៗទាំងអស់ពីលោកខាងលិច ស្ងួតម្បីតែគោលការណ៍ល្អៗ នៃវប្បធម៌លោកខាងលិចក៏ដោយ ។

**បរិបទូបនិយកម្មដ៏សំខាន់:** ដើម្បីឲ្យទទួលផលប្រយោជន៍ពីបរិបទូបនីយ-កម្ម និង ដើម្បីចៀសវាងនូវគ្រោះថ្នាក់ ដែលកើតពីការអូសទាញ ដំណើរការបរិបទូបនីយកម្មត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្ន ។ ខ្ញុំគិតថាភារកិច្ចនៃបរិបទូបនីយកម្ម គួរតែទទួលយកដោយអ្នកដឹកនាំក្នុងស្រុក និង សាសនទូត (យកល្អគឺចេញពីជនជាតិផ្សេងៗ) ជាមួយគ្នាទើបបាន ។ អ្នកដឹកនាំក្នុងស្រុកម្នាក់មានលទ្ធភាពក្នុងការស្វែងយល់ និង មានអារម្មណ៍ដឹងថាអ្វីល្អ ឬ អាក្រក់នៅក្នុងវប្បធម៌របស់ខ្លួន ។ ប៉ុន្តែតួនាទីនៃសាសន-ទូតក៏មានសារៈសំខាន់ណាស់ដែរ ក្នុងការផ្តល់ក្របខ័ណ្ឌអ្វីមួយ ។ មុនពេលធ្វើការជីកបំផុសវប្បធម៌មួយ គេគួរតែស្វែងរកឲ្យយល់ជាមុននូវវប្បធម៌នោះ ។

លោក ខ្រាស្ត[8] ជឿថា ការយល់ដឹងពីវប្បធម៌មួយគឺដូចជាបកសំបកមួយស្រទាប់ម្តង ។ សំបកទី១ គឺការសិក្សាអំពីអាកប្បកិរិយារបស់មនុស្ស សំបកទី២ គឺការយល់ដឹងអំពីតម្លៃរបស់ពួកគេ ។ បន្ទាប់មក អ្នកឈានទៅរកកម្រិតដ៏ជ្រៅមួយ នៃជំនឿដែលពួកគេប្រកាន់យកថា ជាសេចក្តីពិត ។ ទីបំផុត អ្វីដែលជាជម្រៅនៃបេះដូងរបស់វប្បធម៌ណាមួយគឺជា *គតិលោក* របស់ពួកគេនោះឯងគឺអ្វីដែលជាការពិតចំពោះពួកគេ ។ ចំណុចចុងក្រោយនេះ យើងត្រូវតែលើកយកមកពិចារណា នៅពេលប្រកាសដំណឹងល្អ ។

លោក ហេសិលគ្រេវ[9] វែកញែកថា សាសនទូតមានប្រវត្តិវប្បធម៌ផ្ទាល់ខ្លួនគាត់ ដែលតំណាងគតិលោក និង មាត្រដ្ឋាននៃការឲ្យតម្លៃ របស់

---

[8] In an article published in C. H. Kraft and T. N. Wisley. eds., Readings in Dynamic Indigeneity (Pasadena: William Carey Library, 1979).
[9] In an article published in Kraft and Wisley, *Readings*.

គាត់ផ្ទាល់ ។ គាត់ខ្លួនឯងបានទទួលសារពីព្រះគម្ពីរប៊ីប ឋិតក្នុងបរិបទនៃវប្បធម៌ជាក់លាក់របស់គាត់ ។ នេះជា "វប្បធម៌របស់សាសនទូត" ។ គាត់ត្រូវតែបញ្ជូនសារនេះទៅកាន់វប្បធម៌មួយផ្សេងទៀត ជាមួយនឹង គតិលោក និង ប្រព័ន្ធតម្លៃដាច់ដោយឡែករបស់វប្បធម៌នោះ ។ នេះជា "ចំណុចដៅវប្បធម៌គោលដៅ" ។ សេចក្តីល្បួង ដែលកើតមានឡើងក្នុងការបញ្ជាំងប្រវត្តិវប្បធម៌របស់សាសនទូតទៅលើដំណើរការ ហើយធ្វើឲ្យស្រពិចស្រពិលដល់អត្ថន័យដើម នៃសាររបស់ព្រះគម្ពីរប៊ីប ។ សាសនទូត ត្រូវតែលើកយកមកពិចារណានូវចំណុចស្នូល នៃវប្បធម៌ជាមួយនឹងប្រព័ន្ធនៃតម្លៃរបស់វា ។ គាត់ត្រូវតែចងចាំថាគំនិតទាំងឡាយនៃវប្បធម៌នេះមានកម្រិតខ្លាំងក្លាដូចគ្នានឹងវប្បធម៌ផ្ទាល់ខ្លួនរបស់គាត់ដែរ ។ អ្នកស្តាប់គាត់ នឹងផ្តោតការយល់ដឹងផ្ទាល់ខ្លួនរបស់គេ ទៅក្នុងសារនៃព្រះគម្ពីរប៊ីប ។ សាសនទូតត្រូវតែស្ទិតស្ទាញក្នុងការប្រាស្រ័យទាក់ទងតាមមធ្យោបាយមួយ ដែលទាក់ទងយ៉ាងស៊ីជម្រៅដល់វប្បធម៌គោលដៅ នៅពេលដែលគាត់នៅតែរក្សា ដោយស្មោះត្រង់ចំពោះសារដើមដំបូង ។ ភារកិច្ចនេះគឺជា ការងារចំពោះមុខមួយដ៏លំបាកបំផុត ។

ដូច្នេះសាសនទូតមានការទទួលខុសត្រូវធ្ងន់ធ្ងរណាស់ នៅពេលដែលគាត់ដឹកនាំនិងហ្វឹកហ្វឺនអ្នកដឹកនាំក្នុងវប្បធម៌ ដែលគេអើពើទទួលយក ។ គ្រូគង្វាលក្នុងស្រុកជារឿយៗបានបង្ហាញឲ្យឃើញកាន់តែអាក្រក់ឡើងក្នុងការផ្សាយសារនៃដំណឹងល្អបែបលោកខាងលិច ដោយមានការស៊ីចង្វាក់បន្តិចបន្តួចជាមួយវប្បធម៌របស់ពួកគេផ្ទាល់ ។ ផលវិបាកដែលកើតឡើង គឺគ្រោះថ្នាក់ផង និង ស្ថិតស្ថេរផង ។ អ្វីដែលបានចងហើយពិបាកនឹងស្រាយវិញខ្លាំងណាស់ ។

លោក ហេសិលគ្រេវ ជឿថាការប្រាស្រ័យទាក់ទងរវាងសាសនទូតនឹងវប្បធម៌ដែលគេដៅទុក ជាញឹកញយជាល្បោន ដែលតួសំដែងនិយាយតែម្នាក់ឯង-គឺមានន័យថា សាសនទូតនិយាយតែងគ្មានអ្នកឆ្លើយ

តប ។ សាសនទូត មានទំនាក់ទំនងទៅនឹងសារដោយគ្មានការព្យាយាមយល់ពីវប្បធម៌ និង គតិលោក របស់អ្នកឆ្លើយតបសោះ ។

គ្មានផលចំណេញអ្វីកើតឡើងពីការចំអក ឬ ចង្អុលទៅកាន់ភាពមិននឹងនក្នុងជំនឿផ្សេងៗនោះឡើយ ។ សារនៃដំណឹងល្អ ជាសារដែលមានលក្ខណៈសកល ។ សាររបស់គ្រីស្តបរិស័ទនៅតែដូចគ្នា គ្រប់ពេលទាំងអស់ និង គ្រប់វប្បធម៌ទាំងអស់ ។ បរិបទូបនីយកម្មមានសារៈសំខាន់ចំពោះសារដែលគេអាចយល់បាន និង ទទួលយកបាន ។

នៅក្នុងការសិក្សាអំពីករណីពួកជំនុំកម្ពុជា ខ្ញុំចង់ផាត់ចេញទៅម្ខាងនូវទិដ្ឋភាពខាងទេវសាស្ត្រនៃបរិបទូបនីយកម្ម ហើយខ្ញុំចង់សង្កត់ន័យឲ្យខ្លាំងទៅលើរចនាសម្ព័ន្ធបែបស្ថាប័ននៃពួកជំនុំ ដែលមានលក្ខណៈម្ចាស់ការ ។

## ពួកជំនុំកម្ពុជា

សង្គមនីមួយៗ គឺជាប្រព័ន្ធមួយ ។ ដើម្បីនឹងដំណើរការដោយមានប្រសិទ្ធិភាព ប្រព័ន្ធណាមួយក៏ដោយត្រូវតែមានតុល្យភាព និង ស៊ីចង្វាក់គ្នា ។ បើនិយាយតាមលោក ម៉េយើរ ( Mayers) "ផ្នែកទាំងអស់នៃប្រព័ន្ធរមែងទាក់ទិនទៅនឹងប្រព័ន្ធទាំងមូល ហើយផ្តល់អត្ថន័យទៅដល់ប្រព័ន្ធនោះ ។ បើនិយាយបញ្ច្រាសមកវិញ ប្រព័ន្ធទាំងមូលផ្តល់អត្ថន័យដល់ផ្នែកនីមួយៗរបស់ប្រព័ន្ធ ។ បើគ្មានប្រព័ន្ធទាំងមូល នោះផ្នែកនីមួយៗគ្មានហេតុផលអ្វីនឹងនៅស្ថិតស្ថេរបានទេ ហើយបើគ្មានផ្នែកណាមួយរបស់ប្រព័ន្ធទេ នោះក៏គ្មានប្រព័ន្ធទាំងមូលដែរ"[១០] ។

ពួកជំនុំមូលដ្ឋានមួយ ជាផ្នែកខាងវិញ្ញាណនៃអាណាចក្រព្រះផង និង ជាផ្នែកនៃក្រុមសង្គមវប្បធម៌ជាក់លាក់មួយផងដែរ ។ ព្រះជាម្ចាស់

---

[10] M. Mayers, Christianity Confronts Culture (Grand Rapids: Zondervan, 1987), 95.

ត្រាស់ហៅពួកជំនុំគឺ បំផ្លាស់បំប្រែសង្គមបរិយាកាស ដោយសារជំណើងល្អ ដោយមិនចាំបាច់ចម្លងតាមប្រព័ន្ធសង្គមវប្បធម៌បរទេសនោះឡើយ ។

ពួកជំនុំកម្ពុជាអាចបង្ហាញអំពីសុឆន្ទៈ ក្នុងការធ្វើឲ្យពួកជំនុំមានភាពម្ចាស់ការ ចំណែកឯសាសនទូតវិញ កំពុងព្រលែងតួនាទីដឹកនាំដល់គ្រីស្ទបរិស័ទខ្មែរ ។ តែខ្មែរ ដែលមិនមែនជាគ្រីស្ទបរិស័ទវិញ គេនៅតែចាត់ទុកពួកជំនុំខ្មែរថា គ្មានលក្ខណៈជាតិត្រង់ណាសោះ ដោយហេតុថាវប្បធម៌ និង រចនាសម្ព័ន្ធ ដូចជាស្ថាប័នរបស់ពួកជំនុំខ្មែរ មានលក្ខណៈចម្លែកចំពោះមហាជនជាទូទៅពេក ។ កាលដែលជនជាតិខ្មែរម្នាក់ក្លាយខ្លួនមកជាគ្រីស្ទបរិស័ទនោះ មិនមែនជាការងាយស្រួលប៉ុន្មានទេ គឺគាត់មិនគ្រាន់តែពិសោធនូវការផ្លាស់ប្រែខាងវិញ្ញាណប៉ុណ្ណោះទេ គាត់ថែមទាំងត្រូវសម្របខ្លួនតាមវប្បធម៌របស់ពួកជំនុំលោកខាងលិច ។ ដោយហេតុដូច្នេះឯងទើបពួកជំនុំភាគច្រើនមានការពិបាកក្នុងការបង្កើតសិស្ស ចេញពីចំណោមអ្នកជឿថ្មី ។ អ្នកជឿថ្មីអាចមានទំនោរចង់ត្រឡប់ទៅពុទ្ធសាសនាវិញ បន្ទាប់ពីដាក់ខ្លួនមួយរយៈខ្លីក្នុងជំនឿគ្រីស្ទបរិស័ទនោះមក ។ ខ្ញុំគិតថា បាតុភូតនេះកើតឡើងដោយសារយកការអាឡោះអាល័យចំពោះវប្បធម៌ចាស់ ពីព្រោះពួកជំនុំមិនអើពើចំពោះសារៈសំខាន់បរិបទូបនីកម្មរបស់ពួកជំនុំ ។ ខ្ញុំជឿថា ដោយគ្មានការបញ្ចូលបរិបទដ៏ត្រឹមត្រូវទេ គឺគ្មានប្រសិទ្ធិភាពឡើយ ។

**ការរៀនពីប្រវត្តិសាស្ត្រ** សាសនទូតព័រទុយហ្គេ ដូមីនីកាំង បានមកដល់ក្នុងប្រទេសកម្ពុជាក្នុងពាក់កណ្តាលសតវត្សទី ១៦ ។ ពុទ្ធសាសនាបានចូលមកដល់ស្រុកខ្មែរបីបួនសតវត្សមុន ហើយរីកលូតលាស់រហូតទាល់តែស៊ីដាច់សាសនាហិណ្ឌូ ហើយត្រូវបានគេទទួលស្គាល់ថា ជាសាសនាជាតិថែមទៀត ។ ជំនឿគ្រីស្ទបរិស័ទ មិនដែលបានសម្រេចជោគជ័យរបៀបនេះឡើយ ។ ពុទ្ធសាសនាបានទទួលជោគជ័យ ដោយសារការធ្វើឲ្យមានលក្ខណៈម្ចាស់ការនៅក្នុងស្រុក ។

នៅក្នុងឆ្នាំ ១៩៧៥ ព្រះសហគមន៍កាតូលិករ៉ូម៉ាំងមានសមាជិកត្រឹមតែចំនួន ពីរបីរយនាក់ប៉ុណ្ណោះ ក្នុងក្រុមរបស់ខ្លួន ។[៦៦] ការដឹកនាំស្ថិតនៅលើដៃរបស់លោកអភិបាល និង បូជាចារ្យបារាំង ។ គ្រីស្តបរិស័ទកាតូលិក បានទទួលរងការឈឺចាប់យ៉ាងច្រើនក្នុងការបង្កើតវប្បធម៌ព្រះសហគមន៍ក៏ដោយ ក៏សាសនទូតបារាំងហាក់បីដូចជា មិនបានត្រៀមខ្លួននឹងប្រលែងតួនាទីដឹកនាំទៅឲ្យខ្មែរក្នុងស្រុកទេ ។ មានបូជាចារ្យខ្មែរតែពីរ ឬបីនាក់ប៉ុណ្ណោះ ដែលទទួលអគ្គសញ្ញាលាបប្រេងតែងតាំង ហើយមានតែខ្មែរម្នាក់ប៉ុណ្ណោះ ដែលបានទទួលអគ្គសញ្ញាលាបប្រេងតែងតាំងឲ្យធ្វើជាអភិបាលព្រះសហគមន៍ នៅនាទីចុងក្រោយបំផុត ដោយសារតែជនបរទេសត្រូវតែចាកចេញពីប្រទេស មុនពេលខ្មែរក្រហមវាយដណ្តើមយកប្រទេស ក្នុងឆ្នាំ១៩៧៥ ។ ហេតុដូច្នេះ ប្រជាជនខ្មែរមើលឃើញថា ព្រះសហគមន៍កាតូលិកជាសាសនារបស់បារាំង ។

សាសនទូតប្រូតេស្តង់មកពីគ្រីស្តបរិស័ទ និងសម្ព័ន្ធសាសនទូត (CMA ) បានមកដល់ប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩២៣ ។ បេសកកម្មនេះបានផ្តោតយកចិត្តទុកដាក់ លើការធ្វើឲ្យពួកជំនុំមានលក្ខណៈម្ចាស់ការក្នុងស្រុក ។ ពួកជំនុំក្នុងនិកាយនេះមានលក្ខណៈម្ចាស់ការក្នុងស្រុក ។ និកាយនេះបានហើយ និង កំពុងតែអនុវត្តនូវរូបមន្តត្រីស្វយភាពយ៉ាងទូលំទូលាយ ។ ប៉ុន្តែការគ្រប់គ្រងពួកជំនុំនៅតែស្ថិតនៅក្នុងកណ្តាប់ដៃសាសនទូត ហើយរចនាសម្ព័ន្ធរបស់ពួកជំនុំនៅតែផ្តេកផ្តួលទៅតាមគំរូពួកជំនុំ អា

---

[៦៦] *ក្នុងឆ្នាំ ១៩៥៥ ពួកជំនុំកាតូលិករ៉ូម៉ាំង-កម្ពុជាបានមានចំនួនសមាជិក ១២០.០០០ នាក់ ។ ប៉ុន្តែកំឡុងពេលដំណើរការឯករាជ្យឥណ្ឌូចិន បារាំងបានអោយទៅវៀតណាមនូវកូសាំងស៊ីន* (Cochin China) *ដែលធ្លាប់ជាអាណាខេត្តរបស់ខ្មែរ និង ដែលភាគច្រើនពួកកាតូលិកកម្ពុជារស់នៅទីនោះ ។ ការពន្យល់ នេះជាហេតុផលមួយ ដែលកម្ពុជាសម័យមានចំនួនពួកកាតូលិកត្រឹមតែពីរបីរយនាក់ប៉ុណ្ណោះ ។*

មេរិកាំងដដែល ។ ហេតុដូច្នេះ ប្រជាជនខ្មែរមើលឃើញថាពួកជំនុំ ប្រូតេស្តង់ ជាសាសនារបស់អាមេរិកាំង ។

គួរឲ្យស្តាយណាស់ ក្នុងអំឡុងពេលដែល ខ្មែរក្រហមត្រួតត្រាប្រទេសកម្ពុជា (១៩៧៥-១៩៧៩) ប្រទេសទាំងមូលត្រូវធ្លាក់ទៅក្នុងរបបប្រល័យពូជសាសន៍ ព្រះសហគមន៍កាតូលិក និង ប្រូតេស្តង់ទទួលរងវាសនាដូចគ្នា គឺថា លោកអភិបាលព្រះសហគមន៍បូជាចារ្យខ្មែរ និង គ្រូគង្វាលខ្មែរត្រូវខ្មែរក្រហមប្រហារជីវិតចោល ។ ក្នុងចំណោមគ្រូគង្វាលសែសិបនាក់ មានតែបួននាក់តែប៉ុណ្ណោះ ដែលនៅរស់រានមានជីវិត ។ ខ្មែរក្រហមបំផ្លាញពួកជំនុំខ្មែរខ្ទេចខ្ទី ហើយគ្រីស្តបរិស័ទខ្មែរក៏បែកខ្ញែកគ្នាអស់ហើយភាគច្រើនក៏វិនាសបាត់បង់ជីវិតអស់ ។

**ពួកជំនុំកម្ពុជាសម័យបច្ចុប្បន្ន:** ក្រោយពីរបបកុម្មុយនីស្ត បានប្រកាសទទួលស្គាល់ពួកជំនុំនៅកម្ពុជាក្នុងឆ្នាំ ១៩៩១ ពួកគ្រីស្តបរិស័ទដែលនៅរស់ បាននាំគ្នាស្ថាបនាពួកជំនុំឡើងវិញ ។ នៅពេលដែលពួកជំនុំរីកចំរើន និង នៅពេលដែលគ្រីស្តបរិស័ទជាតិឡើងកាន់កាប់ តួនាទីដឹកនាំឡើងវិញ គឺជាពេលដែលត្រូវគិត អំពីបរិបទូបនីយកម្ម នៃរចនាសម្ព័ន្ធរបស់ពួកជំនុំប្រយោជន៍ឲ្យវាស៊ីចង្វាក់គ្នានឹងវប្បធម៌ក្នុងស្រុក ។ សាសនទូតភាគច្រើន និង អ្នកដឹកនាំខ្មែរបានកត់សំគាល់ថា ការផ្សាយដំណឹងល្អទៅកាន់ប្រជាជនខ្មែរមិនពិបាកដូចមុនទៀតទេ តែគឺការថែរក្សាអ្នកជឿ ឲ្យនៅស្មោះត្រង់ក្នុងជីវភាពជាគ្រីស្តបរិស័ទឯនោះទេ ទើបជាការពិបាក ។ នេះគឺជាការពិតដែលពួកអ្នកជឿ មិនដឹងពីរបៀបរស់នៅជាគ្រីស្តបរិស័ទ ក្នុងសង្គមខ្មែរដោយហេតុថារចនាសម្ព័ន្ធរបស់ពួកជំនុំទាំងមូល មានលក្ខណៈបរទេសចំពោះប្រជាជនកម្ពុជា ។ ដូច្នេះ ការពិចារណាពីទ្រង់ទ្រាយ និង លក្ខណៈរបស់ពួកជំនុំខ្មែរ ដើម្បីធ្វើឲ្យប្រជាជនខ្មែរមើលទៅឃើញថាជាពួកជំនុំរបស់ជាតិខ្លួនមិនមែនជាពួកជំនុំបារាំង ឬ អាមេរិកាំងមានសារៈសំខាន់ខ្លាំងណាស់ ។

## ការយល់ដឹងពីរចនាសម្ព័ន្ធសង្គមខ្សែបម៌ខ្មែរ

ជំហានដំបូងនៅក្នុងដំណើរការនេះ គឺការស្វែងយល់ពីរចនាសម្ព័ន្ធរបស់សង្គមខ្មែរ ។ សង្គមខ្មែរត្រូវបានរៀបចំឡើង ស្របទៅតាមបរិយាកាសសង្គមប្រមូលផ្តុំ ។ ឋានានុក្រមមានសារៈសំខាន់ណាស់ ចំពោះប្រជាជនកម្ពុជា ។ ឧទាហរណ៍នៅពេលសាសនទូតចាប់ផ្តើមរៀនភាសាខ្មែរ ពួកគេនឹងទទួលស្គាល់មួយរំពេចថា លក្ខណៈសំគាល់មួយក្នុងចំណោមលក្ខណៈ សំគាល់ចំបងទាំងឡាយរបស់ខ្មែរ គឺចាក់គ្រឹះលើប្រព័ន្ធឋានានុក្រមនេះឯង ដូច្នេះយ៉ាងតិចក៏មានបួនលំដាប់ថ្នាក់នៃវាក្យស័ព្ទខ្មែរដែរ ។ គេមិនអាចនិយាយទៅកាន់ព្រះជាម្ចាស់ ទៅកាន់ស្តេច ទៅកាន់សង្ឃ គ្រូបង្រៀន ឪពុកម្តាយ ឬ មិត្តភក្តិ ដោយប្រើវាក្យស័ព្ទដូចគ្នាបានទេ ។ វាក្យស័ព្ទនីមួយៗ ដែលគេកំណត់រួចមកហើយ ត្រូវបានគេយកមកប្រើសំរាប់លំដាប់ថ្នាក់ជាក់លាក់នីមួយៗនៅក្នុងសង្គម ។

ក្នុងរចនាសម្ព័ន្ធប្រពៃណី ឋានានុក្រមមិនគ្រាន់តែមានមូលដ្ឋានលើតួនាទី ដែលម្នាក់ៗដើរតួនៅក្នុងសង្គមប៉ុណ្ណោះទេ គឺវាផ្អែកលើភាពចាស់ទុំផងដែរ ។ ប្រាជ្ញាច្រើនតែទាក់ទងទៅនឹងអាយុរបស់មនុស្ស ។ តាមធម្មតាមនុស្សវ័យក្មេងមិនសូវមានតួនាទីល្អក្នុងការបង្រៀនមនុស្សចាស់ទេ ។ បេសកកម្មមាននិន្នាការផ្តោតទៅលើការខិតខំប្រឹងប្រែងហ្វឹកហ្វឺនមនុស្សវ័យក្មេង ដោយសារពួកគេមានសមត្ថភាពរៀនតាមរបៀបលោកខាងលិចបានយ៉ាងឆាប់រហ័ស ។ គេមិនសូវអើពើចំពោះមនុស្សវ័យចាស់ប៉ុន្មានទេ ព្រោះគេយល់ឃើញថាការផ្សាយដំណឹងល្អ ឬភារកិច្ចដទៃទៀតក្នុងការបំរើព្រះជាម្ចាស់ គឺជាការងាររបស់មនុស្សវ័យក្មេង ។ អីចឹងហើយបានជា ពួកជំនុំបាត់បង់នូវមធ្យោបាយធម្មតាមួយក្នុងការជះឥទ្ធិពលទៅលើសហគមន៍របស់ខ្លួន ។ នៅក្នុងសង្គមមួយដូចជាប្រទេសកម្ពុជា យើងមិនគួរធ្វេសប្រហែស និង មិនគួរមើលស្រាលចំពោះសារៈសំខាន់របស់មនុស្សវ័យចាស់ឡើយ ។

ចំណុចសំខាន់មួយផ្សេងទៀត ដែលមិនគួរបំភ្លេចចោលនោះ គឺថា ជីវិតខាងឯសាសនា នៅក្នុងប្រទេសកម្ពុជាត្រូវបានរៀបចំឡើងជុំវិញបុព្ជិតនិយម ។ គំនិតស្តីអំពីពួកជំនុំ ដែលជាសង្ឃ ឬ គ្រូគង្វាលមានប្រាក់បៀវត្សរ៍ដោយធ្វើការនៅក្នុងការិយាល័យ មិនធ្លាប់កើតមានឡើងចំពោះប្រជាជនកម្ពុជាទេ ។ ជារឿយៗគ្រូគង្វាលត្រូវបានគេចាត់ទុកថាជានិយោជិតរបស់ក្រុមបេសកកម្ម ឬ អ្នកបំរើការស៊ីវិលច្រើនជាង ជាអ្នកដឹកនាំខាងវិញ្ញាណ ឬ ជាអ្នកដឹកនាំសាសនា ។

## គំរូពីរដែលអាចធ្វើទៅបាន

ការកសាងអាណាចក្រព្រះ មិនគ្រាន់តែតម្រូវឲ្យប្រកាសដំណឹងល្អប៉ុណ្ណោះទេ គឺថែមទាំងការកសាងសហគមន៍នៃអ្នកជឿមួយ ក្នុងស្ថានភាពវប្បធម៌ជាក់លាក់មួយ ។ ពួកជំនុំដែលជាស្ថាប័នសាសនាមួយគួរតែរៀបចំរចនាសម្ព័ន្ធមួយ ដែលមានលក្ខណៈធម្មតាស្របតាមវប្បធម៌ ។ នៅក្នុងសង្គមបែបឋានានុក្រមមួយ "ការចាប់អារម្មណ៍រួមរបស់ក្រុម តែងតែផ្តល់សារៈសំខាន់ ទៅលើថ្នាក់ដឹកនាំ "[១២] ។ ការដឹកនាំពួកជំនុំកម្ពុជាអាចរៀបចំឡើងតាមគំរូពីរ ដូចខាងក្រោមនេះ ៖

១.*ទម្រង់ព្រឹទ្ធាចារ្យនិយម ឬ ទម្រង់ប្រេសប៊ីធីរាន:* នៅក្នុងទំនៀមទម្លាប់ខ្មែរ តួនាទីនៃសិទ្ធិអំណាច និង តួនាទីរបស់ចាស់ទុំ ច្រើនតែជារឿងតែមួយ ។ ជាតួយ៉ាង ស្តេចគឺត្រូវបានគេគោរពមិនគ្រាន់តែ ដោយសារទ្រង់ជាស្តេចប៉ុណ្ណោះទេ ប៉ុន្តែក៏ដោយសារភាពវ័យចាស់ទុំរបស់ទ្រង់ផងដែរ ។ សកម្មភាពខាងសាសនា និង សង្គម ជាធម្មតាត្រូវបានរៀបចំឡើងដោយក្រុម *ឧបាសក ចាស់ទុំ លោកអាចារ្យ* ដែលជាអ្នកដឹកនាំសហគមន៍ពុទ្ធសាសនា ក្នុងការថ្វាយបង្គំ និង ពិធីបុណ្យផ្សេងៗ ។ នៅក្នុងព្រះវិហារ លោកអាចារ្យបំពេញតួនាទីជាអ្នកកណ្តាលរវាងលោកសង្ឃខាងពុទ្ធសាសនា និង ពុទ្ធបរិស័ទចំណុះជើងវត្ត ។

---

[12] Lingenfelter, *Transforming Culture.* 134

ដោយហេតុថា គ្រូគង្វាលគ្រីស្ទបរិស័ទម្នាក់ មើលទៅដូចជាឧបាសកម្នាក់ផ្ទុយពីលោកសង្ឃពុទ្ធសាសនាមួយអង្គ អ្នកមិនជឿហៅគ្រូគង្វាលនោះថា ជាលោកអាចារ្យទៅវិញ ។ ដូច្នេះគេទទួលស្គាល់គ្រូគង្វាលមានសារៈសំខាន់តិចជាងលោកសង្ឃ ។ តាមធម្មតា លោកអាចារ្យមានការងារមនុស្សលោក ។ ប៉ុន្តែការចូលរួមរបស់ពួកគេបិតក្នុងកិច្ចការសាសនា គ្រាន់តែជាការស្ម័គ្រចិត្តប៉ុណ្ណោះ ។

ពួកជំនុំមួយ ដែលរៀបចំដោយមាន "ក្រុមប្រឹក្សាចាស់ទុំ" អាចមានឥទ្ធិពលក្នុងសង្គមច្រើនជាងពួកជំនុំ ដែលមានតែគ្រូគង្វាលម្នាក់ដឹកនាំ ។ រចនាសម្ព័ន្ធបែបនេះ មិនគ្រាន់តែប្រជាជនខ្មែរទទួលស្គាល់ទេ ប៉ុន្តែមូលដ្ឋានរបស់វាឆ្លុះបញ្ចាំងយ៉ាងជិតស្និតទៅនឹងគំរូនៃពួកជំនុំសម័យព្រះគម្ពីរសញ្ញាថ្មី ។ លើសពីនោះទៅទៀត តម្រូវការនៃអ្នកចាស់ទុំក៏យើងបានរកឃើញនៅក្នុងបទគម្ពីរផងដែរ ។[១៣]

២.*ទម្រង់នៃបុព្វជិតនិយម:* តាមទំនៀមទម្លាប់ពីដូនតាមក វត្តអារាមរបស់ប្រជាជនកម្ពុជា មិនគ្រាន់តែជាមជ្ឈមណ្ឌលសាសនាប៉ុណ្ណោះទេ គឺថែមទាំងជាមជ្ឈមណ្ឌលអប់រំ និង ជាខឿននៃសង្គម ដែលក្រុមមនុស្សរស់នៅជាមួយគ្នាជាសហគមន៍ ដើម្បីរៀនសូត្របន់ស្រន់ និង តាំងសមាធិរួមគ្នាជាសហគមន៍ ។ លោកសង្ឃក្មេងៗ ប្រមូលគ្នាជុំវិញលោកសង្ឃចាស់ៗ ហើយប្ដេជ្ញារស់នៅក្នុងភាពក្រខ្សត់ និង ការវៀរចាកកាមកិលេស (យ៉ាងហោចណាស់ ក៏វាមាននៅក្នុងទ្រឹស្ដីមែន) ។ ពួកគេបានចំណាយពេលរបស់ខ្លួន ក្នុងការធ្វើសមាធិ និង សិក្សាគម្ពីរព្រះពុទ្ធសាសនា ។ ប៉ុន្តែមិនដូចជាជីវិត បុព្វជិតនៅក្នុងប៉ែកអឺរ៉ុបទេ សង្ឃយើងទាំងនេះឯណោះវិញធ្វើការប្រាស្រ័យទាក់ទងរាល់ថ្ងៃជាមួយសង្គមមនុស្សក្រៅព្រះវិហារតាមរយៈពិធីផ្សេងៗ និង ការបង្រៀន ។ ពួកសង្ឃក៏ទទួល

---

[១៣] *១ធីម៉ូថេ ៣:១-៧. ទីតុស ១:៥-៩*

អាហារ និង អំណោយពីសំណាក់បណ្ដាជន ។ គំរូនេះអាចឲ្យគ្រីស្ទបរិស័ទខ្មែរ ដែលចង់ប្ដេជ្ញាចិត្ត ចំពោះព្រះជាម្ចាស់ទាំងស្រុង យកមកអនុវត្តតាម ដោយមិនចាំបាច់ផ្ដាច់ខ្លួនចេញពីសង្គមខាងក្រៅឡើយ ។ គេអាចមើលឃើញចំណងទាក់ទងរវាងជីវភាពនេះ និង បទពិសោធន៍របស់ព្រះយេស៊ូ និង ពួកសិស្សរបស់ព្រះអង្គ ។ ពួកសិស្ស បានប្រមូលផ្ដុំគ្នាជុំវិញលោកគ្រូ ដើម្បីរៀនពីគ្រូ និង រក្សាការទាក់ ទងជាមួយសង្គមខាងក្រៅផង ។

នៅក្នុងអតីតកាល ក្រុមបូជាចារ្យ បេណោឌិកទីន បានរៀបចំរបៀបរស់នៅតាមគំរូលោកសង្ឃខ្មែរ ប៉ុន្តែការនេះមិនបានជួយ ឲ្យពួកលោកចំរើនលូតលាស់ឡើយ ។ ខ្ញុំគិតថា នេះជាគំនិតបរិបទូបនីយកម្ម ដែលគ្មានសារៈសំខាន់ ដែលពួកលោកអនុវត្តនូវការធ្វើទុក្ខកិរិយា ដោយចម្លែកចំពោះប្រជាពលរដ្ឋខ្មែរ ។

នៅក្នុងដំណើរការ នៃបរិបទូបនីយកម្ម មានតែទំរង់ខាងក្រៅប៉ុណ្ណោះទេ ដែលត្រូវរៀបចំឡើង តាមរបៀបក្នុងស្រុក ដែលខុសពីនោះប្រហែលជាការផ្សាយដំណឹងល្អ និង វិធីសាស្ត្រនៃការបញ្ចូលទេវសាស្ត្រ ប៉ុន្តែស្នូលនៃដំណឹងល្អ គឺសេចក្ដីសង្គ្រោះ នៅក្នុងព្រះយេស៊ូគ្រីស្ទ ត្រូវតែរក្សាឲ្យនៅដដែល ។ អ្វីដែលពលរដ្ឋខ្មែរ ត្រូវការគឺមិនមែនសាសនាដែលនាំចូលមកពីស្រុកក្រៅ ឬ សាសនានៅក្នុងស្រុកនោះទេ ប៉ុន្តែពួកគេត្រូវការ ការបំផ្លាស់បំប្រែជីវិត ដោយសារដំណឹងល្អវិញ ។

## សរុបសេចក្ដី

ពួកជំនុំក្នុងស្រុកមួយដែលមានលក្ខណៈម្ចាស់ការ មិនមែនគ្រាន់តែជាពួកជំនុំ ដែលដឹកនាំខ្មែរគ្នាឯង ដែលចម្លងយកតាមវប្បធម៌ពួកជំនុំលោកខាងលិច តែប៉ុណ្ណោះទេ ។ ការធ្វើឲ្យពួកជំនុំមានលក្ខណៈម្ចាស់ការក្នុងស្រុក មិនមែនមានន័យថាត្រូវតែបដិសេធចោលនូវគោលការណ៍ និង តម្លៃផ្សេងៗរបស់ពួកជំនុំផ្សេងទៀតនោះទេ ក្នុងនាមយើងជាផ្នែកមួយនៃ

ពួកជំនុំសកលលោក យើងត្រូវតែរស់នៅជាមួយគ្នា ចែករំលែកគ្នានូវការរកឃើញផ្សេងៗ ក្នុងដំណើរជីវិតរបស់យើង ជាមួយព្រះអម្ចាស់ ។ យើងត្រូវតែយល់ជ្រួតជ្រាបផងថា ពួកជំនុំមិនអាចផ្សារភ្ជាប់ទាំងស្រុងជាមួយវប្បធម៌របស់ជាតិខ្លួននោះទេ ។ យើងមិនសម្របខ្លួនទាំងស្រុងទៅតាមសង្គមជាតិរបស់ខ្លួន ក្រែងលោវាបែរជានាំយើងឲ្យវង្វេងចេញពីព្រះ ដែលត្រាស់ហៅយើង ។ ក្នុងដំណើរការនៃការធ្វើឲ្យពួកជំនុំក្នុងស្រុកមានលក្ខណៈម្ចាស់ការ យើងត្រូវតែគិតគូរដល់ ការបំផ្លាស់បំប្រែសង្គមរបស់យើង ដោយនាំយកជីវិតនៃដំណឹងល្អ ទៅក្នុងសង្គមជាជាងនាំយកជីវិតរបស់សង្គមបញ្ចូលក្នុងដំណឹងល្អ "ការបំផ្លាស់បំប្រែមិនមែនជាការធ្វើស្ពាន ដើម្បីចម្លងប្រព័ន្ធមួយទៅ ប្រព័ន្ធមួយទៀតនោះទេ ហើយវាក៏មិនមែនជាការផ្ទេរប្រព័ន្ធគ្រីស្ទបរិស័ទ បញ្ចូលទៅកន្លែងណាមួយ ឬប្រជាជនណាមួយនោះដែរ ។ តាមពិតទៅ ការបំផ្លាស់បំប្រែមានន័យថាការកំណត់អត្ថន័យជាថ្មី ការផ្សារភ្ជាប់ជាថ្មីនៃជីវិតរបស់ពួកជំនុំ ដែលជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ជាមួយនឹងប្រព័ន្ធ ដែលពួកគេឃើញខ្លួនឯងរស់នៅ និងធ្វើការនៅក្នុងនោះ ។"